ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ១០៩១ អយក.ប្រក

# ប្រកាស
## ស្ដីពី
## ការបង្កើតសាលាមត្តេយ្យសិក្សា ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ស្ដីពីការកំណត់ រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ២៤៤ អយក.ប្រក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានអប់រំ
- យោងសំណើសុំបើកសាលាមត្តេយ្យសិក្សា ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត ដែលមានចំណារឯកភាពតាមហានានុក្រម



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតសាលាមត្តេយ្យសិក្សា ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត ដែលមានទីតាំងស្ថិតនៅភូមិពោធិ៍ ឃុំដំណាក់អំពិល ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ ចាប់ពីឆ្នាំសិក្សា២០២៥-២០២៦ ដោយស្ថិតក្រោមរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងនិងចាត់ចែងផ្ទាល់របស់វិទ្យាស្ថានបញ្ញាការសេនាធិការនៃក្រសួងការពារជាតិ។

**ប្រការ២ .-**

នាយកសាលាមត្តេយ្យសិក្សា ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត និងនាយកវិទ្យាស្ថានបញ្ញាការសេនាធិការនៃក្រសួងការពារជាតិ ត្រូវសហការជាមួយរដ្ឋបាលស្រុកសាមគ្គីមុនីជ័យ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺក្នុងការគាំទ្របច្ចេកទេសនិងគរុកោសល្យសម្រាប់ដំណើរការសាលាមត្តេយ្យសិក្សា។

**ប្រការ៣ .-**

សាលាមត្តេយ្យសិក្សា ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត ជាគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈដឹកនាំដោយនាយក១(មួយ)រូប និងនាយករងស្របតាមនិយាមប្រើប្រាស់បុគ្គលិកអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៤ .-**

សាលាមត្តេយ្យសិក្សា ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត ជាគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- អនុវត្តច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងកម្មវិធីគាំទ្រនានាសំដៅធានាគុណភាពសេវាអប់រំកុមារតូច
- ធានាផ្តល់សេវាអប់រំមត្តេយ្យសិក្សាប្រកបដោយគុណភាព ដល់កុមារអាយុចាប់ពី ៣ឆ្នាំ ដល់ក្រោម ០៦ឆ្នាំឬ៧០ខែ ប្រកបដោយសមធម៌ និងបរិយាបន្ន
- អនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា និងសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំថ្នាក់រៀន ទីចាត់ការ សាលប្រជុំ និងបណ្ណាល័យ សម្ភារៈសិក្សាស្របតាមស្តង់ដាគុណភាពអប់រំនិងស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ
- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យអប់រំខេត្តកំពង់ស្ពឺ
- គ្រប់គ្រងបុគ្គលិកអប់រំ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- កៀរគរធនធានពីសប្បុរសជន សហគមន៍ និងដៃគូអភិវឌ្ឍនានា គាំទ្រការអនុវត្តកម្មវិធីនានាដើម្បីលើកកម្ពស់គុណភាពការបង្រៀន និងរៀន
- សហការជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលស្រុកសាមគ្គីមុនីជ័យ មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ

- ធ្វើរបាយការណ៍តាមកាលកំណត់ ជូនរដ្ឋបាលស្រុកសាមគ្គីមុនីជ័យ មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ និងនាយកវិទ្យាស្ថានបញ្ញាការសេនាធិការនៃក្រសួងការពារជាតិ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីនាយកវិទ្យាស្ថានបញ្ញាការសេនាធិការនៃក្រសួងការពារជាតិ មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ រដ្ឋបាលស្រុកសាមគ្គីមុនីជ័យ។

**ប្រការ៥ .-**

សាលាមត្តេយ្យសិក្សា ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត មានសិទ្ធិទទួលមូលនិធិដំណើរការសាលារៀនសាធារណៈឬបេឧបត្ថម្ភផ្សេងៗទៀត និងមានសិទ្ធិប្រើប្រាស់បុគ្គលិកអប់រំ ឬគ្រូកិច្ចសន្យា ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សាលាមត្តេយ្យសិក្សា ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត មានសិទ្ធិកៀរគរធនធានពីសហគមន៍ មាតាបិតា អ្នកអាណាព្យាបាល ដៃគូអភិវឌ្ឍ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជនដើម្បីដំណើរការអភិវឌ្ឍសាលា។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ... 

ភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥

**កន្លែងទទួល៖**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងការពារជាតិ
- រដ្ឋបាលខេត្តកំពង់ស្ពឺ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអប់រំកុមារតូច

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**